**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

**Ministry of Environment**

លេខៈ ១១៦ ប្រក.......បស្ថ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៣

# ប្រកាស
## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "ព្រៃថ្មគោល"
## ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព
## ស្ថិតនៅភូមិអូរកក់ ឃុំពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- បានឃើញលិខិតស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "ព្រៃថ្មគោល" ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៣ តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន។

## <u>សម្រេច</u>

**ប្រការ១** : រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "ព្រៃថ្មគោល" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិអូរកក់ ឃុំពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។

**ប្រការ២** : សហគមន៍តំបន់ការពារធម្មជាតិ "ព្រៃថ្មគោល " ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានទំហំផ្ទៃដីចំនួន **៧៨៣ ហិចតា** ដូចមានផែនទីជាឧបសម្ព័ន្ធ កំណត់ដោយបណ្ដាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោម ៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| S1 | 493108 | 1540283 | S7 | 497280 | 1539883 |
| S2 | 493363 | 1540665 | S8 | 495922 | 1539294 |
| S3 | 493497 | 1541067 | S9 | 495987 | 1538688 |
| S4 | 494829 | 1541237 | S10 | 494890 | 1538068 |
| S5 | 495759 | 1541192 | S11 | 494225 | 1538966 |
| S6 | 497289 | 1540388 | S12 | 493500 | 1539302 |

**ប្រការ៣** :ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "ព្រៃថ្មគោល" នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និង អភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ ស្ដីពីតំបន់ការពារធម្មជាតិ។

**ប្រការ៤** : អគ្គនាយករដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានកម្រងតំបន់ការពារធម្មជាតិ"ស្ទឹងសែន" ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ នាយកដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងសហគមន៍តំបន់ការពារធម្មជាតិ"ព្រៃថ្មគោល" ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា

<u>ចម្លងជូន:</u>
- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -សាលាខេត្តព្រះវិហារ
- -ដូចប្រការ៤ "ដើម្បីអនុវត្ត "
- -ឯកសារ-កាលប្បវត្តិ

ផែនទីសហគមន៍តំបន់ការពារធម្មជាតិ "ព្រៃថ្មគោល" ស្ថិតក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព
ភូមិសាស្ត្រ ភូមិអូរគក់ ឃុំពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ




សញ្ញាសំគាល់

- ចំណុចនិយាមការ
- ទីតាំងសហគមន៍តំបន់ការពារធម្មជាតិ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង, អូរ
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

0 0.5 1 គ.ម

មាត្រដ្ឋាន 1:30,000

Indian_1960_UTM_Zone_48N

| ID | X | Y |
|---|---|---|
| S1 | 493108 | 1540283 |
| S2 | 493363 | 1540665 |
| S3 | 493497 | 1541067 |
| S4 | 494829 | 1541237 |
| S5 | 495759 | 1541192 |
| S6 | 497289 · | 1540388 |
| S7 | 497280 | 1539883 |
| S8 | 495922 | 1539294 |
| S9 | 495987 | 1538688 |
| S10 | 494890 | 1538068 |
| S11 | 494225 | 1538966 |
| S12 | 493500 | 1539302 |